# សុន្ទរកថាស្វាគមន៍

## លោក ...................................... អភិបាលខេត្ត (រង) ខេត្តកំពង់ចាម

ថ្លែងក្នុងពិធីសិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី ១ ស្តីពី

**"អភិក្រមក្របខណ្ឌលើវិស័យពាណិជ្ជកម្ម, លទ្ធផលពាក់កណ្តាលគម្រោង, ការត្រួតពិនិត្យ, ការវាយតម្លៃ និងផលប៉ះពាល់ នៃកម្មវិធីពិពិធកម្មនិងពង្រីកការនាំចេញ ជំហានទី ២** (CEDEP II) **ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម"**

កំពង់ចាម, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៦

វេលាម៉ោង ៖ ០៨៖៣០ ព្រឹក នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម

**សូមគោរព**

- ឯកឧត្តម **ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និង សមាជិកប្រតិភូ នៃក្រសួងពាណិជ្ជកម្ម
- លោក លោកស្រី ប្រធាន-អនុប្រធានមន្ទីរនៃខេត្តទាំងប្រាំពីររួមមាន៖ ខេត្តកំពង់ចាម, ត្បូងឃ្មុំ, ក្រចេះ, ស្ទឹងត្រែង, កំពង់ធំ, មណ្ឌលគីរី និងរតនៈគិរី!
- លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកា នៃអង្គសិក្ខាសាលា ទាំងមូលជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយ ដែលបានអញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាស្វាគមន៍នៅក្នុងកម្មវិធីវគ្គសិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី ១ ស្តីពី **"អភិក្រមក្របខណ្ឌលើវិស័យពាណិជ្ជកម្ម, លទ្ធផលពាក់កណ្តាលគម្រោង, ការត្រួតពិនិត្យ, ការវាយតម្លៃ និងផលប៉ះពាល់ នៃកម្មវិធីពិពិធកម្មនិងពង្រីកការនាំចេញ ជំហានទី ២ (CEDEP II) ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម"។**

ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្នុងនាម ខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះក្រសួងពាណិជ្ជកម្ម ដែលបានជ្រើសយកខេត្តកំពង់ចាម យើងខ្ញុំសម្រាប់រៀបចំវគ្គសិក្ខាសាលាផ្សព្វផ្សាយដ៏មានសារៈសំខាន់នាថ្ងៃនេះ។ ជាពិសេសចំពោះវត្តមានរបស់ **ឯកឧត្តម ម៉ៅ ថូរ៉ា រដ្ឋលេខាធិកានៃក្រសួងពាណិជ្ជកម្ម** និង លោក លោកស្រី អ្នកនាងកញ្ញា ដែលអញ្ជើញមកពីក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (សភាពាណិជ្ជកម្ម, មន្ទីរពាណិជ្ជកម្ម, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, មន្ទីរឧស្សាហកម្ម និងសិប្បកម្ម, មន្ទីរកិច្ចការនារី, មន្ទីរអភិវឌ្ឍន៍ជនបទ, មន្ទីរទេសចរណ៍, មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃខេត្តទាំងប្រាំពីររួមមាន៖ ខេត្តកំពង់ចាម, ត្បូងឃ្មុំ, ក្រចេះ, ស្ទឹងត្រែង, កំពង់ធំ, មណ្ឌលគីរី និងរតនៈគិរី), និងវិស័យឯកជន ដែលជាអ្នកទទួលផលពីគម្រោងដោយផ្ទាល់។

**- ឯកឧត្តម, លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូលជាទីរាប់អាន !**

ស្ថិតក្នុងមនោសញ្ចេតនាដ៏សែនរំភើបរីករាយនេះ ខ្ញុំសូមឆ្លៀតឱកាសដ៏មានតម្លៃ ដើម្បីជម្រាបជូន ឯកឧត្តម គណៈអធិបតី, លោក លោកស្រី សមាជិក សមាជិកា ទាំងមូលមេត្តាជ្រាប អំពី ស្ថានភាពទូទៅ និង សក្តានុពលសំខាន់ៗ ទាក់ទងនឹងវិស័យពាណិជ្ជកម្ម របស់ខេត្តកំពង់ចាមដូចតទៅ ៖

- ✓
- ✓
- ✓

ជាថ្មីម្តងទៀត ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគាំទ្រ យ៉ាងពេញទំហឹងចំពោះការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "**អភិក្រមក្របដណ្តប់លើ វិស័យ ពាណិជ្ជកម្ម, លទ្ធផលពាក់កណ្តាលគម្រោង, ការត្រួតពិនិត្យ, ការវាយតម្លៃ និងផលប៉ះពាល់ នៃកម្មវិធីពិពិធ កម្មនិងពង្រីកការនាំចេញ ជំហានទី ២ (CEDEP II) ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម**" ដែលជា ព្រឹត្តការណ៍ដ៏មានសារៈសំខាន់សម្រាប់ស្ថាប័ន និងភាគី ពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៅតាមបណ្តាខេត្ត ឲ្យទទួលបាននូវព័ត៌មាន និង ចំណេះដឹងថ្មីៗបន្ថែមទៀត ដើម្បីចូលរួមគាំទ្រដល់ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការ ជម្រុញ និងលើកកម្ពស់ការចូលរួមរបស់ស្ថាប័នរដ្ឋ វិស័យឯកជន សហគ្រាសខ្នាតតូច និងមធ្យម ដើម្បី បង្កើនផលិតភាព, ការធ្វើពិពិធកម្ម និងពង្រីកការនាំចេញផលិតផលសក្តានុពលរបស់កម្ពុជា ទៅកាន់ទី ផ្សារក្នុងតំបន់និងអន្តរជាតិឲ្យបានកាន់តែ ច្រើនបន្ថែមទៀត។

ជាចុងបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តម រដ្ឋលេខាធិការ**, លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមវគ្គសិក្ខាសាលាផ្សព្វផ្សាយ និងបានមកស្នាក់នៅលើ ទឹកដីកំពង់ចាមក្នុងរយៈប៉ុន្មានថ្ងៃនេះ។ ខ្ញុំសូមជូនពរ **ឯកឧត្តម** លោក-លោកស្រី គណៈអធិបតី និងភ្ញៀវ កិត្តិយសទាំងអស់មាន សុខភាពល្អ សិរីសួស្តី និងជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**